ភ្នំពេញ ថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## សិក្ខាសាលាស្តីពី
## “បច្ចុប្បន្នភាព នៃការកែទម្រង់ប្រព័ន្ធពន្ធដារកម្ពុជា និងកាតព្វកិច្ចសារពើពន្ធនានា ជាពិសេសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ” ក្រោមអធិបតីភាពរបស់ ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ៨:៣០នាទីព្រឹក ថ្ងៃទី២២ ខែមីនា ឆ្នាំ ២០១៧ ពិធីបើកសិក្ខាសាលាស្តីពី “បច្ចុប្បន្នភាពនៃការកែទម្រង់ប្រព័ន្ធពន្ធដារកម្ពុជា និងកាតព្វកិច្ចសារពើពន្ធនានា ជាពិសេសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ” ក្រោមអធិបតីភាពរបស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមពីសំណាក់ឯកឧត្តមអគ្គនាយករង និងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃអគ្គនាយកដ្ឋានពន្ធដារ និង វត្តមានរបស់ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី តំណាង សមាគម ពាណិជ្ជករនានា និងតំណាងសហគ្រាសអ្នកជាប់ពន្ធធំសរុបចំនួនជាង ១ ០០០ សហគ្រាស។

ឯកឧត្តម **គង់ វិបុល** បានគូសបញ្ជាក់ថា ក្នុងក្របខណ្ឌនៃការកែទម្រង់គោលនយោបាយហិរញ្ញវត្ថុ សាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏ដូចជាអគ្គនា យកដ្ឋានពន្ធដារ មិនមានគោលការណ៍បង្កើតប្រភេទពន្ធថ្មី ឬដំឡើងអត្រាពន្ធបន្ថែម ក្នុងគោលដៅ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

បង្កើនចំណូលថវិកាជាតិនោះទេ ប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារនឹងខិតខំផ្តោតការយកចិត្តទុកដាក់ខ្ពស់ លើការពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ដែលមានជាធរមានឲ្យស្របតាមគោលនយោបាយកែទម្រង់ស៊ីជម្រៅដ៏មុតស្រួចរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ដែលដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានពន្ធដារ ក៏តែងអនុវត្តតាមអនុសាសន៍ របស់ឯកឧត្តមទេសរដ្ឋន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសំដៅធ្វើយ៉ាងណាផ្តល់សេវាជូនអ្នកជាប់ពន្ធឲ្យបានល្អងាយស្រួល ក្នុងការបង់ពន្ធជូនរដ្ឋ ប៉ុន្តែលំបាកក្នុងការគេចវេះ និងបន្លំពន្ធ។

ជាលទ្ធផល ការប្រមូលពន្ធកន្លងមកចាប់ពីឆ្នាំ ២០១២ គឺតែងតែសម្រេចបានលើសផែនការ ហើយការប្រមូលចំណូលពន្ធបានកើនឡើងជាមធ្យមប្រមាណ ២០% ក្នុងមួយឆ្នាំ ដែលជាក់ស្តែងបានកើនប្រមាណពី ៧៣៦ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១២ រហូតទទួលបានប្រមាណជាង ១,៤ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៦។ ដោយឡែកសម្រាប់ឆ្នាំ ២០១៧ គោលដៅប្រមូលចំណូលត្រូវសម្រេចឲ្យបាន ប្រមាណជាង ១,៧ ពាន់លានដុល្លារអាមេរិក និងសម្រាប់ឆ្នាំ ២០១៨ ត្រូវសម្រេចឲ្យបានប្រមាណចន្លោះ ពី ១,៩ពាន់លានដុល្លារ ទៅ ២ ពាន់លានដុល្លារអាមេរិក។

ដើម្បីឆ្លើយតបទៅនឹងផែនការប្រមូលចំណូលពន្ធខាងលើ អគ្គនាយកដ្ឋានពន្ធដារ នាពេលបច្ចុប្បន្ន បាន និងកំពុងខិតខំក្នុងការអនុវត្តយ៉ាងម៉ឺងម៉ាត់ក្នុងការធ្វើកំណែទម្រង់ ទាំងផ្នែករដ្ឋបាលសារពើពន្ធ និងគោលនយោបាយសារពើពន្ធព្រមទាំងពង្រឹងការអនុវត្តច្បាប់ ស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ (RMS) និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ដែលបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាបាននូវអភិបាលកិច្ចល្អ បរិយាកាសធុរកិច្ចដ៏ប្រសើរ និងការប្រកួតប្រជែងដោយស្មើភាពគ្នា (LEVEL PLAYING FIELD) ចំពោះគ្រប់ធុរជន តាមរយៈការប្រមូលចំណូលពន្ធប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងសមធម៌។ ឯកឧត្តមប្រតិភូបាន ក៏បានស្នើសុំសហគ្រាសអ្នកជាប់ពន្ធទាំងអស់ ចូលរួម និងគាំទ្រការពង្រឹងវប្បធម៌នៃការបង់ពន្ធឲ្យបានគ្រប់ៗគ្នា ដើម្បីជំរុញការអភិវឌ្ឍន៍សម្រាប់ប្រទេសយើងទាំងអស់គ្នា។

ដោយឡែក សិក្ខាសាលាថ្ងៃនេះមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីផ្សព្វផ្សាយ និងចែករំលែកព័ត៌មានអំពីវឌ្ឍនភាពថ្មីៗនៃការកំណែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដាររួមមាន÷

(១). ការផ្តល់វិញ្ញាបនបត្រអនុលោមភាពពន្ធ ប្រភេទមាស ជូនសហគ្រាសចំនួន ៣១ ដែលមានអនុលោមភាព



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ពន្ធខ្ពស់ ដែលនឹងទទួលបានអត្ថប្រយោជន៍ដូចជា ទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធមានសុពលភាព ២ឆ្នាំ, ការមិនអនុវត្តពន្ធអប្បបរមា ១% ក្នុងរយៈពេលសុពលភាព, ការអនុវត្តកម្មវិធីសវនកម្មក្នុងរយៈពេល ២ ឆ្នាំម្តង និង ការបង្វិលសងអាករលើតម្លៃបន្ថែមនូវទឹកប្រាក់កម្រិតណាមួយ ដោយមិនចាំបាច់ធ្វើសវនកម្មផ្ទៀងផ្ទាត់ជាមុន។

(២). ការធ្វើបទបង្ហាញអំពីបច្ចុប្បន្នភាពបទប្បញ្ញត្តិស្តីពីពន្ធដារនានារហូតមកដល់ពេលបច្ចុប្បន្ន

(៣). ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងការគ្រប់គ្រងរដ្ឋបាលសារពើពន្ធ សំដៅជំរុញឱ្យមាននូវអភិបាលកិច្ចល្អ ព្រមទាំងបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការផ្តល់សេវាជូនអ្នកជាប់ពន្ធគ្រប់មជ្ឈដ្ឋាន ដោយបង្កលក្ខណៈងាយស្រួល ឆាប់រហ័ស និងមានភាពច្បាស់លាស់ សម្រាប់ទាំងអ្នកជាប់ពន្ធ ។

(៤). ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ គឺដើម្បីស្វែងយល់ឱ្យបានកាន់តែស៊ីជម្រៅថែមទៀត ចំពោះកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធប្រចាំខែ និងប្រចាំឆ្នាំ ជាពិសេសលើប្រាក់ចំណូលប្រចាំឆ្នាំរបស់ខ្លួន ខណៈដែលរដូវកាលនៃការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំនេះ ខិតជិតដល់ថ្ងៃបញ្ចប់នៅដំណាច់ខែមីនាខាងមុខនេះ។

ជាទីបញ្ចប់ ឯកឧត្តម គង់ វិបុល ក៏បានថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក-លោកស្រី ជាតំណាងសមាគមធុរជន និងបណ្តាក្រុមហ៊ុន ទាំងអស់ ព្រមទាំងលោក-លោកស្រី ថ្នាក់ដឹកនាំមន្ត្រីពន្ធដារ និងភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងអង្គសិក្ខាសាលានេះ និងស្នើសូមឱ្យអ្នកចូលរួមទាំងអស់ គាំទ្រការពង្រឹងវប្បធម៌នៃការបង់ពន្ធ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិទាំងអស់គ្នា។ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ក៏បានជូនពរ ឯកឧត្តម-លោកជំទាវ លោកឧកញ៉ា លោក-លោកស្រី សូមសមប្រកបនឹងពុទ្ធិពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ